# កិច្ចប្រជុំក្រុមបច្ចេកទេសលើកទី១ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦

កាលពីព្រឹកថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែ លើកទី១ ប្រចាំឆ្នាំ២០១៦ ក្រោមការដឹកនាំរបស់ ឯកឧត្តមវេជ្ជបណ្ឌិត **តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង-ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ចំនួន៤៥រូប។ ក្នុងកិច្ចប្រជុំនោះផ្តោតការពិភាក្សាទៅលើសកម្មភាព ដែលបានអនុវត្តកន្លងមក និងការបង្ហាញពីគំរោងផែនការសកម្មភាពរបស់ក្រសួងពាក់ព័ន្ធ សំរាប់ការអនុវត្តសកម្មភាពទៅថ្ងៃខាងមុខ។




